# ការទទួលខុសត្រូវលើបច្ចេកវិទ្យា

### ផ្នែកទី ១ ។ ការចំណាយពេលប្រើបច្ចេកវិទ្យាដោយឈ្លាសវៃ

នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ព្រះអម្ចាស់ប្រើពាក្យ « ឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ » និង « បង្ខាត » ។

- តើអ្នកគិតថា ពាក្យទាំងនេះមានន័យដូចម្ដេច ?

សូមអានបទគម្ពីរខាងក្រោម ហើយជញ្ជឹងគិតពីអ្វីដែលព្រះអម្ចាស់បង្រៀនអំពីការឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ និងការបង្ខាត ៖ គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៨:២៧–២៨; ៦០:១៣; ៦៨:៣១; ៧៥:៣ ។

- តើអ្នកនឹងសង្ខេបអ្វីដែលព្រះអម្ចាស់បង្រៀនយ៉ាងដូចម្ដេច ?

( នៅក្នុងចំណោមសេចក្ដីពិតមួយចំនួន អ្នកអាចសង្កេតឃើញអ្វីមួយដូចខាងក្រោមនេះ ៖ ព្រះអម្ចាស់មានព្រះទ័យចង់ឲ្យយើងឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ ហើយមិនបង្ខាតពេលវេលារបស់យើងឡើយ ) ។

- តើយើងអាចដឹងថា បើយើងខ្ជះខ្ជាយពេលវេលារបស់យើងជាមួយបច្ចេកវិទ្យាដោយរបៀបណា ?

សូមសិក្សាសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដោយរកមើលការយល់ដឹងអំពីការប្រើប្រាស់បច្ចេកវិទ្យាដោយឈ្លាសវៃ ។

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



[ បុគ្គល ] ម្នាក់ដែលមិនទាន់ពេញវ័យ ឬមានការយល់ខុសអាចចំណាយពេលវេលាមិនសមហេតុផលក្នុងការលេងហ្គេម មើលវីដេអូ ឆែតតាមអនឡាញ ឬតាមរបៀបផ្សេងទៀតដែលអនុញ្ញាតឲ្យឌីជីថលគ្រប់គ្រងរឿងទាំងឡាយតាមដែលមាន ។ ដំបូងឡើយ ការចំណាយពេលវេលានោះអាចហាក់ដូចជាគ្មានការបង្កគ្រោះថ្នាក់អ្វីទេ ដោយគ្រាន់តែគិតថា ត្រូវការពេលពីរបីនាទីដើម្បីដកឃ្លាពីតម្រូវការការងារប្រចាំថ្ងៃដ៏មមាញឹកប៉ុណ្ណោះ ។ ប៉ុន្តែឱកាសសំខាន់ៗត្រូវបានខកខានសម្រាប់ការអភិវឌ្ឍ និងការកែលម្អជំនាញទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ។ . . . បន្តិចម្ដងៗ ការកម្សាន្តដែលហាក់ដូចជាគ្មានកំហុសអ្វីសោះអាចក្លាយជាទម្រង់នៃការធ្វើជាទាសករដ៏អាក្រក់ ។ ( ដេវីឌ អេ បែដណា « Things as They Really Are » *Ensign* ខែមិថុនា ឆ្នាំ ២០១០ ទំព័រ២១ )

- តើមនុស្សប្រើហេតុផលអ្វីខ្លះដើម្បីបង្ហាញពីការខ្ជះខ្ជាយពេលវេលាលើបច្ចេកវិទ្យា ?
- តើអ្វីដែលជួយអ្នកឲ្យចៀសវាងពីការខ្ជះខ្ជាយពេលវេលារបស់អ្នកទៅលើបច្ចេកវិទ្យា ?
- តើអ្នកអាចដាក់បញ្ចូលព្រះអម្ចាស់យ៉ាងដូចម្ដេចក្នុងការខិតខំរបស់អ្នកដើម្បីប្រើបច្ចេកវិទ្យាដោយឈ្លាសវៃ ?

### ផ្នែកទី ២ ។ ការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយល្អ

- តើអ្នកជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះជាប្រចាំ ?
- តើបទពិសោធន៍របស់អ្នកបានបង្រៀនអ្នកអ្វីខ្លះ ដែលអាចជួយអ្នកឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅពេលអ្នកធ្វើការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយ ?

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៥០:២៣–២៤; មាត្រានៃសេចក្ដីជំនឿ ១:១៣ និង មរ៉ូណៃ ៧:១២–១៧ ដោយរកមើលសេចក្ដីពិតដែលអាចជួយយើងវិនិច្ឆ័យរឿងល្អ និងរឿងអាក្រក់បាន ។

- តើអ្នករកឃើញសេចក្ដីពិតអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ?

( ក្នុងចំណោមសេចក្ដីពិតមួយចំនួន អ្នកអាចកំណត់សេចក្ដីពិតមួយដូចតទៅ ៖ អ្វីដែលពង្រឹង និងបញ្ចុះបញ្ចូលឲ្យធ្វើល្អគឺមកពីព្រះ ) ។

- តើអ្នកអាចទទួលបានអត្ថប្រយោជន៍យ៉ាងណាពីការអនុវត្តសេចក្ដីពិតនេះ ពេលអ្នកជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយណាដែលត្រូវប្រើ ?

អែលឌើរ ដេវីឌ អេ បែដណាបានអញ្ជើញយើងឲ្យសួរខ្លួនឯងនូវសំណួរខាងក្រោមអំពីប្រព័ន្ធផ្សព្វផ្សាយដែលយើងប្រើ ៖



តើការប្រើបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗអញ្ជើញ ឬរាំងភាពជាដៃគូដ៏ខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់អ្នកដែរឬទេ ? ( ដេវីឌ អេ បែដណា « Things as They Really Are » *Ensign* ខែមិថុនា ឆ្នាំ២០១០ ទំព័រ២៣ )

- __តើអ្នកអាចយាងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកធ្វើការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយដោយរបៀបណា ?
- តើអ្វីជួយអ្នកឲ្យចៀសវាងពីប្រភេទប្រព័ន្ធផ្សព្វផ្សាយដែលអាចនាំអ្នកចេញឆ្ងាយពីព្រះអង្គសង្គ្រោះ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_554-1